ជំងឺធ្លាក់ទឹកចិត្តអាចកើតមានជាទូទៅ ប៉ុន្តែវាគឺជាជំងឺធ្ងន់ធ្ងរ ហើយកើតមានឡើងជាញឹកញាប់ (មានន័យថា បានធូរស្រាល ហើយបែរជាកើតមានឡើងវិញនៅចន្លោះពេលណាមួយក្រោយមកទៀត)។

**គំនូសបំព្រួញជំងឺធ្លាក់ទឹកចិត្ត**




បុគ្គលអាចមានអារម្មណ៍ក្រៀមក្រំ កណ្ដោចកណ្ដែងនៅពេលខ្លះ។ ជាធម្មតាវាមានហេតុផលច្បាស់លាស់ចំពោះអារម្មណ៍បែបនេះដូចជា៖ បាត់បង់មនុស្សជាទីស្រឡាញ់ឬអ្វីមួយជាដើម។ ភាពក្រៀមក្រំនិងភាពសោកសៅ គឺជាប្រតិកម្មធម្មជាតិ និងជាបណ្ដោះអាសន្នដែលឆ្លើយតបទៅនឹងព្រឹត្តការណ៍តានតឹងចិត្ត។ បុគ្គលភាគច្រើន អាចបានធូរស្រាលវិលត្រឡប់មករកសភាពធម្មតាវិញ ដោយពុំចាំបាច់ទទួលការព្យាបាលឡើយ។

ទោះជាយ៉ាងនេះក្ដី ប្រសិនបើភាពក្រៀមក្រំនៅបន្តកើតមានរយៈយូរជាងធម្មតា ហើយប៉ះពាល់លើសមត្ថភាពរបស់បុគ្គលក្នុងការបំពេញការងារ ឬទំនាក់ទំនង បុគ្គលនោះអាចកើតមានជំងឺធ្លាក់ទឹកចិត្ត។

## ១. សញ្ញាសំគាល់បុគ្គលមានជំងឺធ្លាក់ទឹកចិត្ត

ប្រសិនបើបុគ្គលមានជំងឺធ្លាក់ទឹកចិត្ត យ៉ាងហោចណាស់រោគសញ្ញាចំនួន២ ក្នុងចំណោមរោគសញ្ញាខាងក្រោម នឹងកើតមានយ៉ាងតិចរយៈពេល២សប្ដាហ៍៖

- អារម្មណ៍ក្រៀមក្រំខុសពីធម្មតាមានជាប់ជាប្រចាំ
- បាត់បង់ចំណង់ចំណូលចិត្ត និងភាពរីករាយនៅក្នុងសកម្មភាពដែលធ្លាប់ចូលចិត្តពីមុន
- បាត់បង់ថាមពល និងគ្មានកំលាំងកំហែង

**អ្នកជំងឺធ្លាក់ទឹកចិត្ត គតថា៖ ជីវតគ្មានន័យ អស់សង្ឃឹម គ្មានទីពឹង ចង់ធ្វើអត្តឃាត...**



**លើសពីនេះ រោគសញ្ញាបន្ទាប់បន្សំដទៃទៀតអាចកើតមានឡើង៖**

- បាត់បង់ទំនុកចិត្តលើខ្លួនឯងឬឲ្យតម្លៃខ្លួនទាប
- មានអារម្មណ៍បន្ទោសខ្លួនឯង
- មានបំណងចង់ស្លាប់
- ពិបាកផ្ចង់អារម្មណ៍ ឬធ្វើការសម្រេចចិត្ត
- មានចលនាយឺត ឬជួនកាលបែរជាឡេះឡះ និងមិនអាចសំរួលវាបាន
- ពិបាកក្នុងការគេង ឬជួនកាលគេងច្រើនជ្រុល
- បាត់បង់ចំណង់បរិភោគឬជួនកាលហូបច្រើនជ្រុល

មិនមែនគ្រប់បុគ្គលដែលមានជំងឺធ្លាក់ទឹកចិត្ត សុទ្ធតែលេចចេញនូវរោគសញ្ញាទាំងអស់នេះឡើយ។ បុគ្គលដែលមានជំងឺធ្លាក់ទឹកចិត្តកម្រិតធ្ងន់ធ្ងរ នឹងកើតមានរោគសញ្ញាកាន់តែច្រើន ជាងបុគ្គលដែលមានជំងឺធ្លាក់ទឹកចិត្តកម្រិតស្រាល។

## ២. មូលហេតុនៃជំងឺធ្លាក់ទឹកចិត្ត

ជំងឺធ្លាក់ទឹកចិត្តមិនមានមូលហេតុតែមួយឡើយ។ បុគ្គលអាចកើតមានជំងឺធ្លាក់ទឹកចិត្ត នៅពេលមានអ្វីមួយធ្វើឲ្យមានអារម្មណ៍ក្រៀមក្រំជាខ្លាំង ហើយពួកគេមិនអាចធ្វើអ្វីសោះដើម្បីគ្រប់គ្រងស្ថានភាពនោះដូចជា៖

- បែកបាក់ទំនាក់ទំនងឬរស់នៅក្នុងស្ថានភាពជំលោះ
- សម្រាលកូន(១០-១៥%នៃស្ត្រីកើតមានជំងឺធ្លាក់ទឹកចិត្តរយៈពេលខ្លីបន្ទាប់ពីសម្រាលកូន)
- បាត់បង់ការងារ ហើយលំបាកស្វែងរកការងារថ្មី
- ជួបគ្រោះថ្នាក់បណ្ដាលឲ្យពិការភាពរយៈពេលយូរ
- ជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម
- កើតមានជំងឺផ្លូវកាយរ៉ាំរ៉ៃ
- ថែទាំពេញម៉ោងចំពោះអ្នកជំងឺរ៉ាំរ៉ៃ

### ជំងឺធ្លាក់ទឹកចិត្តក៏អាចបណ្តាលមកពីៈ

- ផលរំខាននៃឱសថ
- ភាពតានតឹងបណ្តាលមកពីជំងឺផ្លូវចិត្តដទៃទៀតៈ ជំងឺចិត្តវិកល ថប់បារម្ភ ញៀនសុរា/គ្រឿងញៀន
- ការផ្លាស់ប្តូរកម្រិតអរមូននៅមុនពេលមានរដូវ

## ៣. ការព្យាបាល

- ជំងឺធ្លាក់ទឹកចិត្តអាចព្យាបាលបានធូរស្បើយដ៏ឆាប់រហ័ស នៅពេលទទួលបានអន្តរាគមន៍ដ៏ត្រឹមត្រូវ។
- វិធីព្យាបាលត្រូវអនុវត្តអមគ្នាទាំងឱសថ(ថ្នាំ) និងការព្យាបាលតាមបែបចិត្តសាស្ត្រ(ផ្តល់ប្រឹក្សា)។

## ៤. របៀបជួយ

- ជំងឺធ្លាក់ទឹកចិត្តមិនមែនជាជំងឺមិនគ្រប់ទឹក ឬអន់ខ្សោយ ឬក៏ខ្ជិលច្រអូសឡើយ។
- អនុញ្ញាតឲ្យបុគ្គលនោះ និយាយពីអារម្មណ៍របស់ខ្លួន ដែលកំពុងកើតមាន។
- ស្តាប់ដោយមិនវិនិច្ឆ័យដើម្បីស្វែងយល់ពីបញ្ហា
- សូមកុំរិះគន់ និងមិនត្រូវបង្ហាញការខកចិត្តរបស់អ្នក ចំពោះបុគ្គលមានរោគសញ្ញាធ្លាក់ទឹកចិត្ត។
- ចំពោះករណីធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ ត្រូវនាំអ្នកជំងឺទៅព្យាបាលជាមួយអ្នកឯកទេសវិជ្ជាជីវៈ៕

### សំគាល់: ក្រុមគ្រួសារគប្បីៈ

⇒ ឃ្លាំមើលអ្នកជំងឺជាប់ជាប្រចាំ ពីព្រោះអ្នកជំងឺអាចមានគំនិតធ្វើអត្តឃាត(សម្លាប់ខ្លួន)។

⇒ ត្រូវយកវត្ថុ ឬរបស់របរដែលអាចបង្កនូវគ្រោះថ្នាក់ចេញឲ្យឆ្ងាយពីអ្នកជំងឺដូចជាៈ ខ្សែ កន្ត្រៃ ឬកាំភ្លើងជាដើម ដើម្បីការពារពីការសម្លាប់ខ្លួន។



**គ្រួសារនិងមិត្តភក្តិមានតួនាទីដ៏សំខាន់ក្នុងការគាំទ្រផ្លូវចិត្តដល់បុគ្គលមានជំងឺធ្លាក់ទឹកចិត្ត**

**ដោយបំណាចល្អពីអង្គការធីភីអូ-កម្ពុជា**

**អគារៈ** អគារលេខ២&៤ ផ្លូវឧកញ៉ាវ៉ាំង(១៩៥២) សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

(016) 222 597 / 095 777 004 (ផ្នែកគ្លីនិក)

(023) 63 66 992 (ផ្នែករដ្ឋបាល)

វិបសាយៈ www.tpocambodia.org

# ជំងឺធ្លាក់ទឹកចិត្ត

(DEPRESSION)



ការធូរស្បើយកើតមានឆាប់រហ័សបាន លុះត្រាតែអ្នកជំងឺមានអារម្មណ៍ថា ទទួលបាននូវកម្លាំងចិត្ត និងការគាំទ្រពីអ្នកជុំវិញខ្លួន

រៀបរៀងដោយ ឧបត្ថម្ភដោយ

TPO
Transcultural Psychosocial Organization
Community Mental Health Programme

Else Kröner Fresenius Stiftung

LOUVAIN COOPERATION